**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៣៧៧៣១...អពដ

L202511190409TD3526

ថ្ងៃអង្គារ ១២ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការលុបចោលអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន សំរិទ្ធិ អឺខោនធីង អេន មេនេចម៉ិន ឯ.ក (នាមករណ៍បច្ចុប្បន្ន ស៊ី.អូ.អេស.ធី.វី ខេមរា អឺខិនធីង ឯ.ក)

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅជ្រាបថា អគ្គនាយកដ្ឋានពន្ធដារបានសម្រេចលុបចោលអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន **សំរិទ្ធិ អឺខោនធីង អេន មេនេចម៉ិន ឯ.ក** (SAMRITH ACCOUNTING AND MANAGEMENT CO., LTD.) **(នាមករណ៍បច្ចុប្បន្ន ស៊ី.អូ.អេស.ធី.វី ខេមរា អឺខិនធីង ឯ.ក)** (C.O.S.T.V KHEMERA ACCOUNTING CO.,LTD) លេខអត្តសញ្ញាណកម្មសារពើពន្ធ K008-901701391 លេខអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ TA201807003 គិតចាប់តាំងពីកាលបរិច្ឆេទនៃលិខិតជូនដំណឹងនេះតទៅ។ តាមរយៈការសម្រេចនេះ ក្រុមហ៊ុនត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបដល់លោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យ និងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅ ជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**